**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១២១ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# រូបសញ្ញានិងត្រារបស់គណៈកម្មាធិការជាតិសម្រាប់ការសិក្សាពេញមួយជីវិត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២០/៩២៤ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិសម្រាប់ការសិក្សាពេញមួយជីវិត
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ២៣៧ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរបស់គណៈកម្មាធិការជាតិសម្រាប់ការសិក្សាពេញមួយជីវិត
- យោងតាមសំណូមពរចាំបាច់នៃការងារ

## សម្រេច

**មាត្រា១ .-**

ត្រូវបានបង្កើតរូបសញ្ញានិងត្រារបស់គណៈកម្មាធិការជាតិសម្រាប់ការសិក្សាពេញមួយជីវិត(**គ.ជ.ស.ជ.**) សម្រាប់ប្រើក្នុងដំណើរការការងាររបស់ខ្លួន។

**មាត្រា២ .-**

រូបសញ្ញារបស់ **គ.ជ.ស.ជ.** មានរូបភាពនិងអត្ថន័យដូចខាងក្រោម៖

- រូបមនុស្ស៣នាក់ប្រកៀកស្មាគ្នា មានពណ៌បៃតងខ្ចី ពណ៌បៃតងចាស់ និងពណ៌ផ្ទៃមេឃ តំណាងឱ្យវ័យទាំង៣នៃមនុស្សជាតិ គឺបឋមវ័យមនុស្សពណ៌បៃតងខ្ចីតំណាងឱ្យជីវិត វ័យវឌ្ឍនាការ និងការសិក្សា, មជ្ឈិមវ័យមនុស្សពណ៌បៃតងចាស់តំណាងឱ្យភាពពេញវ័យនិងភាតរភាព និងបច្ឆិមវ័យមនុស្សពណ៌ផ្ទៃមេឃតំណាងឱ្យភាពចាស់ទុំនិងគតិបណ្ឌិត
- រូបស្លឹករំដួលពណ៌បៃតងជាកម្រងអមរូបមនុស្ស តំណាងឱ្យប្រភពធនធាននៃភាពលូតលាស់របស់ជីវិត ជារុក្ខជាតិតំណាងកម្ពុជាប្រៀបដូចជាធនធានសម្រាប់ជាតិខ្មែរយើង
- រូបសៀវភៅពណ៌បៃតងទ្រពីក្រោមមានឆ្លាក់អក្សរពណ៌ផ្ទៃមេឃ **គ.ជ.ស.ជ.** តំណាងឱ្យប្រភពនៃចំណេះដឹងប្រកបដោយគម្ពីរភាព ជាគ្រូបាធ្យាយនៃវិជ្ជាសព្វសារពើទាំងពួង ដោយមានសរសេរឈ្មោះជាអក្សរសង្ខេប **គ.ជ.ស.ជ.**។

រូបសញ្ញាដែលមានខ្លឹមសារដូចមានចែងខាងលើ ជាឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

**មាត្រា៣ .-**

រូបសញ្ញារបស់ **គ.ជ.ស.ជ.** ត្រូវបានប្រើដូចខាងក្រោម៖

- ដាក់នៅកន្លែងធ្វើការរបស់ **គ.ជ.ស.ជ.**
- ដាក់នៅលើក្បាលលិខិតផ្លូវការរបស់ **គ.ជ.ស.ជ.** និងអគ្គលេខាធិការដ្ឋាន **គ.ជ.ស.ជ.**
- ប្រើក្នុងដំណើរការការងាររបស់ **គ.ជ.ស.ជ.**។

**មាត្រា៤ .-**

ត្រារបស់ **គ.ជ.ស.ជ.** មានទម្រង់ដូចខាងក្រោម៖

- មានរាងជារង្វង់មូលទំហំ៣៦(សាមសិបប្រាំមួយ)មីលីម៉ែត្រ
- មានខ្សែព័ទ្ធខាងក្រៅ២ជាន់និងមានខ្សែខាងក្នុង១ជាន់
- នៅចំកណ្តាលមានរូបប្រាសាទអង្គរវត្តកំពូល៣ ហើយនៅខាងក្រោមសរសេរជាអក្សរកាត់ **គ.ជ.ស.ជ.**
- ក្នុងរង្វង់ផ្នែកខាងលើឆ្លាក់អក្សរថា **ព្រះរាជាណាចក្រកម្ពុជា** ស្របតាមវណ្ឌ និងផ្នែកខាងក្រោមឆ្លាក់អក្សរថា **គណៈកម្មាធិការជាតិសម្រាប់ការសិក្សាពេញមួយជីវិត** ស្របតាមវណ្ឌ និងនៅចន្លោះពាក្យទាំងពីរមានរូបផ្កាចន្ទន៍អមសងខាង។

ត្រាដែលមានខ្លឹមសារដូចមានចែងខាងលើ ជាឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងប្រធានគណៈកម្មាធិការជាតិសម្រាប់ការសិក្សាពេញមួយជីវិត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៣រោច ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១នៃអនុក្រឹត្យលេខ ១២១ អនក្រ.បក ចុះថ្ងៃទី ៦ ខែមិថុនា ឆ្នាំ២០២៣
ស្តីពីរូបសញ្ញានិងត្រារបស់គណៈកម្មាធិការជាតិសម្រាប់ការសិក្សាពេញមួយជីវិត(**គ.ជ.ស.ជ.**)

## រូបសញ្ញារបស់ គ.ជ.ស.ជ.

ឧបសម្ព័ន្ធទី២នៃអនុក្រឹត្យលេខ ១២១ អនក្រ.បក ចុះថ្ងៃទី ៦ ខែមិថុនា ឆ្នាំ២០២៣
ស្តីពីរូបសញ្ញានិងត្រារបស់គណៈកម្មាធិការជាតិសម្រាប់ការសិក្សាពេញមួយជីវិត(គ.ជ.ស.ជ.)

## ត្រារបស់ គ.ជ.ស.ជ.

